លេខ៖ D202/2

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 04 / 08 / 2014
ម៉ោង (Time/Heure) : 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៤

ភាសា ៖ ខ្មែរ/អង់គ្លេស [ភាសាដើម អង់គ្លេស]

ចំណាត់ថ្នាក់ឯកសារ ៖ ~~សម្ងាត់~~ សាធារណៈ / Public

---

## *ដីកាសម្រេចលើសំណើរបស់ [redacted] ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឲ្យបញ្ចូលនូវការដាក់ឯកសារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម*

---

**<u>ផ្ញើជូន</u>**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងជនសង្ស័យ**
សូ មូស្សេរីនី
Suzana TOMANOVIC

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
គង់ ផល្លៈ
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ

Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Mahdev MOHAN
Barnabe NEKUI
Lyma NGUYEN
Philippine SUTZ

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២00៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩(" ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[1]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដាក់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២0១១[2]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២0១៤[3]។

**បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពានក្រមព្រហ្មទណ្ឌ **ឆ្នាំ ១៩៥៦ អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២0៩, ២១0, ៥00, ៥0១, ៥0៣, ៥0៤, ៥0៥, ៥0៦, ៥0៧, និង ៥0៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

**បានឃើញ** វិធាន ១៤(២), ២១, ៣៩, ៥៥, ៧២, ៧៤ និង៧៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") និងមាត្រា៧ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (វិសោធនកម្មលើកទី ៨)។

---

[1] សំណុំរឿង00៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣")។ សំណុំរឿង00៤ ឯកសារD1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩។

[2] សំណុំរឿង 00៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២0១១។

[3] សំណុំរឿង 00៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២0១៤។

**បានពិចារណាទៅលើ** *សំណើរបស់* [redacted] *ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់ឯកសារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម* ("សំណើ")[4]។

**បានឃើញ** កំណត់ហេតុនៃករណីខ្វែងយោបល់គ្នាចុះថ្ងៃទី ២២ ខែ កុម្ភៈ និង ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣។

**ប្រវត្តិនីតិវិធី**

១. សំណើបានដាក់នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៤ រួមជាមួយនឹងឧបសម្ព័ន្ធមួយដែលមានបញ្ជីឯកសារពាក់ព័ន្ធដាក់ដោយមេធាវីជនសង្ស័យ[5]។ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤ ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានដាក់សំណើចូលក្នុងសំណុំរឿង ហើយបានជូនដំណឹងសហមេធាវីរបស់ [redacted] ("ជនសង្ស័យ") និង "មេធាវីជនសង្ស័យ" ថា "*តាមសេចក្តីណែនាំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សំណើរបស់លោក-លោកស្រី បានដាក់ចូលក្នុងសំណុំរឿង ហើយនឹងត្រូវឆ្លើយតបក្នុងពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន*"[6]។

**សារណា**

២. មេធាវីជនសង្ស័យ ស្នើសុំ សហចៅក្រមស៊ើបអង្កេត "*បង្គាប់ទៅក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ឱ្យបញ្ចូលនូវការដាក់ឯកសារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនបានបញ្ចូល ឬបញ្ចូលដោយយឺតយ៉ាវនូវការដាក់ឯកសារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿង។ ហេតុនេះ*

[4] សំណុំរឿង ០០៤ ឯកសារ D202 *សំណើរបស់យឹម ទិត្យ ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់សារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម* ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៤។

[5] សំណុំរឿង ០០៤ ឯកសារ D202 *សំណើរបស់* [redacted] *ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់សារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម តារាងសិទ្ធិអំណាច* ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៨-១៧។

[6] សំណុំរឿង ០០៤ ឯកសារ D202/1 *ការឆ្លើយតបរបស់ក្រឡាបញ្ជីទៅនឹងសំណើរបស់* [redacted] *ទៅសហចៅក្រមស៊ើបអង្កេតសុំបង្គាប់ទៅក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យបញ្ចូលនូវការដាក់សារនានារបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងភ្លាម* ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤។

01003979



*មេធាវីការពារក្តី ត្រូវបានបដិសេធមិនឱ្យមានឱកាសបញ្ចូលឯកសាររបស់ខ្លួនជាកំណត់ហេតុភ្លាមៗ ឬត្រូវបានបដិសេធមិនឱ្យមានឱកាសបញ្ចូលឯកសាររបស់ខ្លួនជាកំណត់ហេតុតែម្តង ដែលទង្វើនេះគឺជាការរំលោភបំពានដល់សិទ្ធិជាសារវ័ន្តរបស់[redacted]"*[7]។

៣. នៅក្នុងការគាំទ្រសំណើ មេធាវីជនសង្ស័យ បញ្ជាក់ថា៖

- អនុលោមតាមសន្ទានុក្រមនៃវិធាន សំណុំរឿងចាំបាច់ត្រូវមាន "កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ"។ មេធាវីការពារក្តីមានការពាក់ព័ន្ធក្នុងនីតិវិធី។ ការដាក់ឯកសារនានាពីអ្នកដែលពាក់ព័ន្ធក្នុងរឿងក្តី *ក្នុងចំណោមនោះ* បង្កើតបានជាកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី។ ការដាក់ឯកសារទាំងនេះត្រូវតែបញ្ចូលក្នុងសំណុំរឿង[8]។

- បើតាមការយល់ឃើញរបស់មេធាវីការពារក្តី គឺថា ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនបានបញ្ចូលសំណើសុំប្រកាសមោឃភាពទៅក្នុងសំណុំរឿងទេ ទោះជាភ្លាមៗក្តី ឬមិនបានបញ្ចូលទាល់តែសោះតែម្តង។ សំណើសុំប្រកាសមោឃភាពមិនទាន់ត្រូវបានចុះបញ្ជីទេ។ ពុំមានកំណត់ហេតុនៃសំណើសុំប្រកាសមោឃភាពនៅក្នុងសំណុំរឿងទេ។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស បានរំលោភវិធាន ៧៦(៣)[9]។

- ពុំមានបញ្ញត្តិណាមួយផ្តល់ឆន្ទានុសិទ្ធិដល់ក្រឡាបញ្ជីសម្រេចថាតើ ឬនៅពេលណាដែលត្រូវបញ្ចូលការដាក់ឯកសារទៅក្នុងសំណុំរឿងនោះទេ។ ពុំមានសេចកក្តីសម្រេចណាមួយពីសហចៅក្រមស៊ើបអង្កេតបានសម្រេចអ្វីផ្សេងពីនេះទេ។ ជាងនេះទៀត វិធានក៏មិនអនុញ្ញាតឱ្យចៅក្រម ចេញសេចក្តីសម្រេច ឬដីកាបង្គាប់មិនឱ្យបញ្ចូលការដាក់ឯកសារទៅក្នុងសំណុំរឿងដែរ[10]។

- ដូចមានការពន្យល់ក្នុងឧបសម្ព័ន្ធ ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងបំពេញការងារតាមទំនើងចិត្តក្នុងការសម្រេចថាតើ ឬនៅពេលណាដែលគាត់ត្រូវបញ្ចូលការដាក់ឯកសារ

---

[7] សំណើ សេចក្តីផ្តើម។

[8] សំណើ កថាខណ្ឌ ២៧។

[9] សំណើ កថាខណ្ឌ ៣០។

[10] សំណើ កថាខណ្ឌ ៣១។

01003980



របស់មេធាវីការពារក្ដីទៅក្នុងសំណុំរឿង។ ពុំមានមូលដ្ឋានណាមួយមកសំអាងពីមូលហេតុដែលឲ្យក្រឡាបញ្ជីរបស់ ក.ស.ច.ស ត្រូវដាក់ការដាក់ឯកសាររបស់មេធាវីការពារក្ដីទៅក្នុងសំណុំរឿងយឺតយ៉ាវទេ ប្រសិនបើគាត់បានដាក់បញ្ចូលការដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿងនោះ។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនបានផ្ដល់ការពន្យល់គ្រប់គ្រាន់អំពីការបំពេញការងារតាមទំនើងចិត្តនេះទេ[11]។

- ដើម្បីការពារក្ដីរបស់ខ្លួន [redacted] ត្រូវដាក់ឯកសាររបស់ខ្លួនបញ្ចូលទៅក្នុងសំណុំរឿង។ ដើម្បីទទួលបានសិទ្ធិបញ្ចេញយោបល់ [redacted] ត្រូវដាក់ឯកសាររបស់ខ្លួនបញ្ចូលក្នុងសំណុំរឿង។ ការមិនបានដាក់ឯកសាររបស់មេធាវីការពារក្ដីភ្លាមៗទៅក្នុងសំណុំរឿង ឬមិនបានដាក់ទាល់តែសោះ (មានមហន្តរាយជាក់ស្ដែង)ប្រសិនបើក្រឡាបញ្ជីរបស់ ក.ស.ច.ស នៅតែបន្តធ្វើទៅតាមទម្លាប់អនុវត្តនាពេលបច្ចុប្បន្ននេះ) ក្រឡាបញ្ជីរបស់ ក.ស.ច.ស កំពុងរំលោភបំពានទៅលើសិទ្ធិរបស់[redacted] ក្នុងការការពារក្ដីរបស់ខ្លួន[12]។

- ដើម្បីឲ្យ[redacted] បានអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការប្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣) និងយុត្តិសាស្ត្រនៅ អ.វ.ត.ក នោះ គាត់ត្រូវតែអាចធ្វើកំណត់ហេតុយ៉ាងពិប្រាកដ ដែលបញ្ចូលនូវកំហុសលើអង្គច្បាប់ អង្គហេតុ ឬការបំពានឆន្ទានុសិទ្ធិក្នុងការពិនិត្យលើបណ្ដឹងឧទ្ធរណ៍[13]។

## ពិភាក្សា

### ក. លទ្ធភាពទទួលសំណើ

៤. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អន្តរជាតិ") យល់ឃើញថា ជនសង្ស័យមានសិទ្ធិដាក់សំណើនេះ ពីព្រោះថា សំណើនេះលើកឡើងពីសេចក្ដីព្រួយបារម្ភពាក់ព័ន្ធអំពីនីតិវិធីដើម្បីឲ្យជនសង្ស័យនានាដាក់ឯកសារ។

---

[11] សំណើ កថាខណ្ឌ ៣៤។

[12] សំណើ កថាខណ្ឌ ៣៦។

[13] សំណើ កថាខណ្ឌ ៣៨។

01003981



## ខ. ការដាក់ឯកសារដោយភាគីនានានៅក្នុងកិច្ចដំណើរការនីតិវិធី

៥. ស.ច.ស.អន្តរជាតិ កត់សម្គាល់ថា ជាគោលការណ៍ទូទៅ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បង្គាប់ឱ្យក្រឡាបញ្ជីរបស់ ក.ស.ច.ស ដាក់ឯកសារទាំងអស់របស់ភាគីនានានៅក្នុងកិច្ចដំណើរការនីតិវិធី (និងជនផ្សេងទៀតដែលមានសិទ្ធិ)ចូលក្នុងសំណុំរឿងស៊ើបអង្កេតដោយគ្មានការពន្យារពេល។ ពិតណាស់ ការដាក់ឯកសារភ្លាមៗចូលក្នុងសំណុំរឿង ធានាឱ្យមានតម្លាភាព និងផ្តល់ការជូនដំណឹងអំពីបញ្ហានានាដែលបានលើកឡើងទៅជូនភាគីផ្សេងទៀត ដូច្នេះអាចឱ្យភាគីផ្សេងទៀតមានឱកាសឆ្លើយតប។ ទោះយ៉ាងណា គួរបង្ហាញថា ស.ច.ស មានតែសិទ្ធិស៊ើបអង្កេតស្ថិតនៅក្នុងដែនកំណត់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ដូច្នេះ ស.ច.ស អាចបដិសេធមិនដាក់ឯកសាររបស់ភាគីនានាចូលក្នុងសំណុំរឿង ក្នុងកាលៈទេសៈពិសេស ក្នុងករណីដែលកម្មវត្ថុនៃការដាក់ឯកសារនោះស្ថិតនៅក្រៅដែនកំណត់អង្គហេតុ និងនីតិវិធីនៃការស៊ើបអង្កេតរបស់តុលាការ[14]។ ពិតណាស់ ការអនុវត្តគោលការណ៍នេះគឺអាស្រ័យជាពិសេសទៅលើលក្ខខណ្ឌតម្រូវរដ្ឋបាល ដូចជា តម្រូវការឱ្យ ស.ច.ស កំណត់ផ្នែកសមស្របនៃសំណុំរឿង និងកម្រិតនៃភាពសម្ងាត់ដើម្បី ដាក់ឯកសារនីមួយៗ។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនអនុវត្តឆន្ទានុសិទ្ធិណាមួយនៅក្នុងដំណើរការនេះទេ។ គាត់អនុវត្តតាមសេចក្តីណែនាំដែលទទួលបានពី ស.ច.ស[15]។

## គ. ការដាក់ឯកសារដោយជនសង្ស័យនានា

[14]សូមមើល ការបដិសេធរបស់ ស.ច.ស មិនយល់ស្របនឹងបំណងដាក់សំណៅថតចម្លងមួយច្បាប់នៃពាក្យបណ្តឹងរបស់មេធាវីការពារក្តីនៅចំពោះតុលាការក្រុងភ្នំពេញ៖ សំណុំរឿង ០០២ ឯកសារ D124/1 *ដីកាបដិសេធសំណើសុំដាក់ឯកសារទៅក្នុងសំណុំរឿង* ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩។ ការបដិសេធសំណើសុំបង្ហាញការពិត "*អំពីតុលាការនេះ*"៖ សំណុំរឿង ០០២ ឯកសារ D158/5 [សាធារណៈ] *ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩ កថាខណ្ឌ ៨-១១។ សំណុំរឿង ០០២ ០០២ ឯកសារ D158/5/4/14 [សាធារណៈ] *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ខ្លួន ជា* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ កថាខណ្ឌ ២៤-៣១។

[15] សំណើ កថាខណ្ឌ ៣១។

៦. ដោយសារគោលការណ៍នេះ មិនមានកាតព្វកិច្ចដែលត្រូវធ្វើ"កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី"[16]ឡើយសម្រាប់ការដាក់ឯកសារដោយជនដែលមិនមានសិទ្ធិនៅចំពោះមុខ អ.វ.ត.ក។ នៅក្នុងដីកាសម្រេចរបស់គាត់លើសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ០០៤ និងសុំការអនុញ្ញាតចូលរួមការស៊ើបអង្កេត ចេញនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ("ដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង") [17] ស.ច.ស.អន្តរជាតិ បានបញ្ជាក់សាឡើងវិញថា វិធានផ្ទៃក្នុងបែងចែកយ៉ាងច្បាស់រវាងជនសង្ស័យ ជាមួយនឹងជនត្រូវចោទ ហើយផ្តល់ឱ្យជនត្រូវចោទនូវសិទ្ធិទំលំទូលាយជាង[18]។ ពិតណាស់ ដោយមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី ជនសង្ស័យមិនមានសិទ្ធិចូលពិនិត្យមើលកំណត់ហេតុសម្ងាត់នៃការស៊ើបអង្កេត ហើយក៏មិនមានសិទ្ធិដាក់សំណើសុំមោឃភាព អនុលោតាមវិធានផ្ទៃក្នុង ៧៦[19] ឬក៏ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរដែរ[20]។ អាស្រ័យហេតុនេះ សិទ្ធិរបស់ជនសង្ស័យ ក្នុងការ "បញ្ចេញយោបល់"[21] នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី គ្រាន់តែមានត្រឹមសិទ្ធិដែលទទួលបានដោយជនសង្ស័យ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ២១តែប៉ុណ្ណោះ។

៧. ដោយសារសិទ្ធិមានកំណត់របស់ជនសង្ស័យនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់តុលាការ ការដាក់សារណារបស់ជងសង្ស័យណាម្នាក់ចូលក្នុងផ្នែកខ្លឹមសារ (ផ្នែក ឃ)នៃសំណុំរឿង និងការឆ្លើយតបនានា គឺអាស្រ័យទៅលើការកំណត់ជាមុនអំពីឋានៈរបស់គាត់នៅក្នុងការស៊ើបអង្កេត។ នៅក្នុងរឿងក្តីបច្ចុប្បន្ន ទើបតែនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ប៉ុណ្ណោះ

---

[16] សំណើ កថាខណ្ឌ ២៧។

[17] សំណុំរឿង ០០៤ ឯកសារ D186/3 *ដីកាសម្រេចលើសំណើបន្ទាន់របស់មេធាវីការពារក្តី*[redacted]*សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបសួរ* ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ថាខណ្ឌ ៣១។

[18] *ដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង* កថាខណ្ឌ ២៦។ សំណុំរឿង ០០៤ ឯកសារ D121/4 សាធារណៈ *[កោសលុប]សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារក្តីសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦។

[19] *ដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង* កថាខណ្ឌ ២៤ និង៣២។

[20] សំណុំរឿង ០០៤ ឯកសារ D190 *ដីកាសម្រេចលើសំណើ [របស់ជនសង្ស័យ] សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៤-៥។

[21] សំណើ កថាខណ្ឌ ៣៦។

ដែល ស.ច.ស.អន្តរជាតិ បានបញ្ជាក់ថា ជនសង្ស័យ បច្ចុប្បន្ននេះមិនមែនជាជនត្រូវចោទនៅក្នុងសំណុំរឿង ០០៤ ដូច្នេះមិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ[22]។

៨. នៅពេលដែល ស.ច.ស.អន្តរជាតិ បានកំណត់ថា ជនសង្ស័យណាម្នាក់មិនមែនជាជនត្រូវចោទ សេចក្តីសម្រេចនានាថាតើត្រូវដាក់ឯកសាររបស់គាត់ចូលក្នុងសំណុំរឿងឬអត់នោះ ត្រូវតែធ្វើឡើងតាមករណីនីមួយៗ ដោយអាស្រ័យលើថាតើជនសង្ស័យមានសិទ្ធិដាក់សារណាប្រភេទនោះឬអត់[23]។ ឧទាហរណ៍ នៅក្នុងសេចក្តីសម្រេចមួយលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលបានដាក់ដោយជនសង្ស័យម្នាក់ទៀតនៅក្នុងសំណុំរឿង ០០៤ ("ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ")[24] ស.ច.ស.អន្តរជាតិ បានសម្រេចថា *"ប្រសិនបើគ្មានការប្រែប្រួលឋានៈរបស់ជនសង្ស័យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងមិនទទួលយក ហើយក៏មិនដាក់ចូលក្នុងសំណុំរឿងនូវសំណើបន្ថែមទៀតដែលដាក់តាងនាមឱ្យជនសង្ស័យដើម្បីស្នើឱ្យអនុវត្តសិទ្ធិដែលវិធានផ្តែក្នុងរក្សាទុកឱ្យជនត្រូវចោទ"*[25]។

៩. បន្ថែមពីលើនេះទៀត ការដាក់ឯកសារមួយចំនួនត្រូវបានស្នើឡើងតែជាភាសាអង់គ្លេស ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។ សំណើបែបនេះតម្រូវឱ្យមានការពិចារណាផ្នែកតុលាការថាតើកាលៈទេសៈពិសេស ដូចជា ភាពបន្ទាន់នៃការឆ្លើយតបទៅនឹងសំណើនេះ មានយុត្តិកម្ម មិនគោរពតាមលក្ខខណ្ឌតម្រូវដែលថា រាល់ឯកសារទាំងអស់ត្រូវដាក់នៅចំពោះមុខ អ.វ.ត.ក ជាភាសាខ្មែរ ព្រមទាំងជាភាសាអង់គ្លេស ឬបារាំង[26]។

១០. ដោយសារមូលហេតុទាំងអស់នេះ រយៈកាលនៃពេលវេលានឹងមានការខុសគ្នាយ៉ាងច្បាស់រវាងកាលបរិច្ឆេទដែលជនសង្ស័យណាម្នាក់ ដាក់សារណាណាមួយ ជាមួយនឹងការសម្រេចរបស់ ស.ច.ស ទាក់ទងនឹងការដាក់សារណានោះចូលក្នុងសំណុំរឿង។ ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនមានឥទ្ធិពលទៅលើដំណើរការនេះឡើយ ហើយគាត់ក៏មិនអនុវត្តឆន្ទានុសិទ្ធបែបនេះដែរ។

---

[22] *ដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង* កថាខណ្ឌ ២៨។

[23] សំណើ កថាខណ្ឌ ៣១។

[24] សំណុំរឿង ០០៤ ឯកសារ D190 *ដីកាសម្រេចលើសំណើ [របស់ជនសង្ស័យ] សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១៤។

[25] ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ៦។

[26] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (វិសោធនកម្មលើកទី ៨) មាត្រា ៧.១ និង ៧.២ ។

១១. អាស្រ័យហេតុនេះ ការចោទប្រកាន់របស់មេធាវីជនសង្ស័យអំពីការអនុវត្តតាមទំនើងចិត្តរបស់ក្រឡាបញ្ជី ក.ស.ច.ស[27] គឺគ្មានមូលដ្ឋាន។ លើសពីនេះទៀត ភាពខុសគ្នាបែបនោះខាងពេលវេលានៃសេចក្តីសម្រេចស្តីពីការដាក់ចូលក្នុងសំណុំរឿង គឺមិនរំលោភបំពានលើសិទ្ធិជាសារវ័ន្តរបស់ជនសង្ស័យឡើយ ពីព្រោះថា ភាពខុសគ្នាបែបនោះគឺដោយសារចាំបាច់ត្រូវកំណត់ថាតើការដាក់ឯកសារណាមួយ បាន ឬក៏មិនបានលើកឡើងពីបញ្ហានានាពាក់ព័ន្ធនឹងសិទ្ធិដែលនៅជាប់ជាមួយនឹងឋានៈរបស់គាត់[28]។

## ឃ. ការរក្សាទុកកំណត់ហេតុ

១២. ទោះយ៉ាងណា គ្រាន់តែដើម្បីរក្សាទុកកំណត់ហេតុតែប៉ុណ្ណោះ ប្រសិនបើជនសង្ស័យណាម្នាក់ត្រូវបានសម្រេចថាមានសិទ្ធិនៅក្នុងករណីណាមួយ ឬ ប្រសិនបើឋានៈរបស់គាត់ជាជនសង្ស័យបានផ្លាស់ប្តូរនៅដំណាក់កាលក្រោយមកទៀត នោះ ស.ច.ស.អន្តរជាតិ បានសម្រេចថា ជាការសមស្របដែលត្រូវដាក់សារណាទាំងអស់របស់ជនសង្ស័យចូលក្នុងផ្នែកឯកសាររដ្ឋបាល (ផ្នែក"ក")នៃសំណុំរឿង។ ការអនុវត្តនេះបានអនុវត្តរួចហើយ។ ឧទាហរណ៍ ស.ច.ស. អន្តរជាតិ បានបង្គាប់ក្រឡាបញ្ជីរបស់ ក.ស.ច.ស មិនឱ្យដាក់សំណើបន្ថែមទៀតពីជនសង្ស័យម្នាក់ទៀតនៅក្នុងសំណុំរឿង ០០៤ ចូលក្នុងផ្នែកខ្លឹមសារនៃសំណុំរឿង ០០៤ ឡើយ ដោយនៅពេលនោះ សំណើនេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៅក្នុងការជូនដំណឹងផ្នែករដ្ឋបាលរបស់ក្រឡាបញ្ជី[29]។

១៣. នៅក្នុងរឿងក្តីបច្ចុប្បន្ន ស.ច.ស.អន្តរជាតិ កត់សម្គាល់ថា ដោយសារថា ឋានៈរបស់ជនសង្ស័យត្រូវបានសម្រេចនៅក្នុងដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង ទើប

---

[27] សំណើ កថាខណ្ឌ ៣៤។

[28] សំណើ កថាខណ្ឌ ៣៨។

[29] សំណុំរឿង ០០៤ ឯកសារ A117 *សេចក្តីជូនដំណឹងស្តីពីសំណើទីបួន [របស់ជនសង្ស័យ]សុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤។ និងឧបសម្ព័ន្ធ ០០៤/A117/1 ។ នីតិវិធីនេះក៏កំពុងតែអនុវត្តនៅក្នុងសំណុំរឿង ០០៣ ផងដែរ។ សំណុំរឿង ០០៣ ឯកសារ D108/1 *ដីកាសម្រេចលើសំណើ[របស់ជនសង្ស័យ]សុំដាក់សំណើសុំពិចារណាទាំងអស់ចូលក្នុងសំណុំរឿង* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤។

01003985



ភាគច្រើនក្នុងចំណោមឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសំណើ បានដាក់ចូលក្នុងផ្នែកខ្លឹមសារនៃសំណុំរឿង និង/ឬបានឆ្លើយតបរួចហើយ[30]។

១៤. ទាក់ទងនឹងសំណើនៅសល់របស់ជនសង្ស័យដែលស្នើសុំមោឃភាព ដោយអនុលោមតាមវិធានផ្ទៃក្នុង ៧៦[31] សេចក្តីសម្រេចផ្នែកតុលាការ បានធ្វើរួចហើយនៅក្នុងដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង គឺថា ជនសង្ស័យ មិនមានសិទ្ធិដាក់សំណើបែបនោះឡើយ[32]។ អាស្រ័យហេតុនេះ សំណើនោះត្រូវតែដាក់ចូលក្នុងផ្នែករដ្ឋបាល (ផ្នែក "ក")នៃសំណុំរឿង ខណៈដែលរង់ចាំការប្រែប្រួលណាមួយទៅលើឋានៈរបស់ជនសង្ស័យ។

**តាមសំអាងហេតុខាងលើ ខ្ញុំ** MARK B. HARMON **៖**

១៥. **បង្គាប់ឲ្យ** ក្រឡាបញ្ជីរបស់ ក.ស.ច.ស

- ដាក់ពាក្យសុំដូចបានលើកយោងក្នុងកថាខណ្ឌ ១៤ ខាងលើ ចូលក្នុងសំណុំរឿង ០០៤ ផ្នែកឯកសាររដ្ឋបាល(ផ្នែក"ក")នៃសំណុំរឿង ព្រមទាំងសារណាទាំងអស់នាពេលអនាគតរបស់ជនសង្ស័យនានា ដើម្បីរក្សាទុកកំណត់ហេតុខណៈដែលរង់ចាំសេចក្តីសម្រេចលើឋានៈរបស់ជនសង្ស័យនានា

---

[30] សំណុំរឿង ០០៤ ឯកសារ D203 *សំណើរបស់*[redacted]*សុំការបញ្ជាក់ថា គាត់អាចអនុវត្តការស៊ើបអង្កេតដោយខ្លួនឯងបាន* ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៤។ សំណុំរឿង ០០៤ ឯកសារ D203/1 *ដីកាសម្រេចទាក់ទងនឹងសំណើរបស់*[redacted]*សុំការបញ្ជាក់ថា គាត់អាចអនុវត្តការស៊ើបអង្កេតដោយខ្លួនឯងបាន* ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤។

- សំណុំរឿង ០០៤ ឯកសារ D205 *សំណើរបស់*[redacted] *ស្នើសហចៅក្រមស៊ើបអង្កេត ផ្តល់ការយល់ឃើញរបស់ខ្លួនអំពីច្បាប់ប្រសិនបើមានករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនៅពេលដែលចេញដីកាដំណោះស្រាយ* ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ និងសំណុំរឿង ០០៤ D205/1 *ដីកាសម្រេចលើសំណើរបស់* [redacted] *សុំការបំភ្លឺទាក់ទងនឹងដីកាដំណោះស្រាយប្រសិនបើមានករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត* ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤។
- បន្ថែមពីលើនេះ ដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង បានឆ្លើយតបទៅនឹងការដាក់ឯកសារលេខ 004-D186 និងលេខ 004-D186/2។

[31] *ពាក្យសុំរបស់*[redacted] *ស្នើសហចៅក្រមស៊ើបអង្កេត ឲ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ សំណើសុំមោឃភាពកិច្ចស៊ើបសួរ* ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។ បានលើកយោងនៅក្នុងសំណើ ត្រង់កថាខណ្ឌ ៣០។

[32] ដីកាសម្រេចលើការចូលពិនិត្យមើលសំណុំរឿង កថាខណ្ឌ ១៩ និង៣២។

- ផ្តល់ជូនមេធាវីជនសង្ស័យនូវសំណៅចតចម្លងនានានៃករណីច្បាប់សម្ភាត់ដែលបានលើកយោងនៅក្នុងដីកាសម្រេចនេះជាសំណៅដែលមានការកោសលុបតាមការចាំបាច់ សម្រាប់តែគោលបំណងនៃដីកាសម្រេចនេះតែប៉ុណ្ណោះ និង

១៦. **បដិសេធផ្នែកផ្សេងទៀតទាំងអស់នៃសំណើ។**

ភ្នំពេញ ថ្ងៃទី៤ ខែ សីហា ឆ្នាំ ២០១៤

**ចៅក្រម Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**